**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

**ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា**

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# សេចក្តីសម្រេចកែសម្រួលលើកទី ០១
# លើឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅ សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល

# សម្រាប់ការកែសម្រួលម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ

## DECISION ON THE FIRST REVISION

TO THE LICENSE DOCUMENT No. 050 LD DATED September 09, 2003
FOR PROVIDING ELECTRIC POWER SERVICES AT SANGKAT PREKTHMEY
KHAN MEANCHEY PHNOM PEHN AND KHUM CHHEU TEAL, KEANSVAY
DISTRICT, KANDAL PROVINCE

## FOR REVISING THE OWNERSHIP OF LICENSEE

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤**

**June 13, 2014**

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ៖ ២២៤ សរ -១៤.អអក

# សេចក្តីសម្រេចកែសម្រួលលើកទី០១
# លើឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣

# DECISION ON THE FIRST REVISION
# TO THE LICENSE DOCUMENT No. 050 LD DATED SEPTEMBER 09, 2003

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03, dated 02/February/2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣

- In accordance with License Documents No. 050 LD issued by Electricity Authority of Cambodia on September 09, 2003.

-យោងលិខិតស្នើសុំផ្ទេរសិទ្ធិគ្រប់គ្រងអាជ្ញាប័ណ្ណរបស់លោកស្រី វង្ស សោភ័ណ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៤

- In accordance with the requested letter for transfering the licensee of Mrs. Vong Sorphorn, dated February 08, 2014.

-យោងតាមការអនុម័តរបស់សម័យប្រជុំ**អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី២៦២ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

- In accordance with the decision of Electricity Authority of Cambodia's Session No.262, dated June 13, 2014.

# សម្រេច
# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ ដែលបានផ្តល់ជូន សហគ្រាស **រីកូ**(បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") ដើម្បីកែសម្រួលឧបសម្ព័ន្ធទី៣" ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ " នៃឯកសារអាជ្ញាប័ណ្ណលេខ ០៥០ឯអ ស្របតាមលិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ៧៨៤៩. ពណ.ចពប ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ | **Article 1**<br>To revise the license document No. 050 LD dated September 09, 2003, which was issued to **REECO** (hereinafter referred to as **"Licensee"**) for revising schedule 3 " Ownership of Licensee" of license document No.050 LD in conformity with letter of Ministry of Commerce No. 7849 dated December 31st, 2013. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី ៣ ចាស់ " ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ " លើឯកសារ អាជ្ញាប័ណ្ណលេខ ០៥០ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី ៣ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 3 "Ownership of Licensee "of the license document No. 050 LD is replaced by the new revised schedule 3 attached herewith. |
| **ប្រការ៣**<br>ខ្លឹមសារនិងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 3**<br>The other contents and conditions of the license document No. 050 LD shall remain in force. |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ។ | **Article 4**<br>This decision shall be considered as a part of the license documents No.050 LD. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ បានតម្កល់ទុកពីមុនដើម្បីឲ្យឯកសារអាជ្ញាប័ណ្ណលេខ ០៥០ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 050 LD has been deposited in order that the deposited license document No. 050 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

Phnom Penh, June 13, 2014

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ទី នរិន្ទ**

# ឧបសម្ព័ន្ធទី ៣
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ
# ធ្វើការកែសម្រួល ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី ២៦២ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

## SCHEDULE 3

## OWNERSHIP OF LICENSEE

## AS REVISED IN SESSION OF EAC No.262 DATED JUNE 13, 2014

| | |
|---|---|
| ១- សហគ្រាស **រីកូ** គឺជាសហគ្រាសឯកបុគ្គល ដែលមានលោក **ទ្រី សុគន្ធ** ជាឯកកម្មសិទ្ធិករ ។<br>២- យោងតាមមាត្រា៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុនឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឲ្យបានក្នុងករណីពិសេស ដើម្បីជាផលប្រយោជន៍សាធារណៈ ។ | 1. Mr. **Try Sokun** is the single owner of the **REECO** enterprise.<br>2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without Written permission from EAC. EAC may permit in Special cases in public interest. |